**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ...១៤៩.ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារ ដែនសមុទ្រត្រួតគ្នាកម្ពុជា - ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**ប្រការ១** : បង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារ ដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម | **វ៉ា គឹមហុង** | ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែន | អនុប្រធាន |
| ៣- | ឯកឧត្តម | **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | អនុប្រធាន |
| ៤- | ឯកឧត្តម | **ហូ ទិចិត្រ** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | អនុប្រធាន |
| ៥- | ឯកឧត្តម | **ហេង ទខ្យប៊ុនណាត** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់<br>ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា | ទីប្រឹក្សាជាន់ខ្ពស់ |

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៦- | ឯកឧត្តម | **ច័ន្ទ តានី** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ទីប្រឹក្សាជាន់ខ្ពស់ |
| ៧- | ឯកឧត្តម | **ប្រុក សារឿន** | ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអគ្គលេខាធិការរង គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | ទីប្រឹក្សាជាន់ខ្ពស់ |
| ៨- | ឯកឧត្តម | **ជា ម៉ាន់ដេត** | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ៩- | ឯកឧត្តម | **ឡុង វិសាលោ** | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០- | ឯកឧត្តម | **ឡាំ ជា** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១១- | ឯកឧត្តម | **វង្សី វិស្សុត** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២- | ឯកឧត្តម | **គឹមរ៉េត សំរេច** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣- | ឯកឧត្តម | **ហ៊ីង ថុរ៉ាក់ស៊ី** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤- | ឯកឧត្តម | **សុខ ខាម៉ាន់** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៥- | ឯកឧត្តម នាយឧត្តមនាវី | **ទៀ វិញ** | មេបញ្ជាការកងទ័ពជើងទឹក និងជាអគ្គលេខាធិការ គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | សមាជិក |
| ១៦- | ឯកឧត្តម | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧- | ឯកឧត្តម | **សុខ សុភាន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | សមាជិក |
| ១៨- | ឯកឧត្តម | **ឆា ដុប** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៩- | ឯកឧត្តម | **កៅ ធារ៉ូ** | អនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២០- | ឯកឧត្តម | **គុណ ញឹម** | អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២១- | ឯកឧត្តម | **ជៀម សួរ** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២២- | ឯកឧត្តម | **គង់ ច័ន្ទវាសនា** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |
| ២៣- | ឯកឧត្តម | **ហាក់ សុខហេង** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

**ប្រការ២:** គណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាតនៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ មានភារកិច្ច ៖

(ក)- ចរចារៀបចំសន្ធិសញ្ញា ប្រព័ន្ធច្បាប់គ្រប់គ្រងបទប្បញ្ញត្តិ គោលការណ៍ លិខិតបទដ្ឋានទាំងឡាយ ពាក់ព័ន្ធ នឹងការអភិវឌ្ឍរួមគ្នា នៃធនធានប្រេងកាត ដែលមានផលប្រយោជន៍ទៅវិញទៅមក និងអាចទទួលយកបាន ដោយភាគីទាំងពីរ ក្នុងការបែងចែកការចំណាយ និងផលចំណេញ នៃការធ្វើអាជីវកម្មធនធានប្រេងកាត ដែលស្ថិតនៅក្នុងតំបន់នៃការអភិវឌ្ឍរួមគ្នា ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច។

(ខ)- ចរចារៀបចំសន្ធិសញ្ញា កំណត់ព្រំដែនសមុទ្រ ដែនដីខ្ពង់រាបបាតសមុទ្រ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែលស្ថិតចន្លោះបន្ទាត់ នៃការទាមទារអះអាងដែនសមុទ្របច្ចុប្បន្នរៀងៗខ្លួន របស់

ប្រទេសទាំងពីរ នៅក្នុងតំបន់ដែលត្រូវបែងចែកព្រំដែន អនុលោមទៅតាមបណ្តា គោលការណ៍ទាំងឡាយ ដែលអាចអនុវត្តបាននៃច្បាប់អន្តរជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច។

(គ)- ផ្អែកលើតម្រូវការចាំបាច់ គណៈកម្មាធិការបច្ចេកទេសចម្រុះនេះ ត្រូវចុះអង្កេតផ្ទៀងផ្ទាត់រួមគ្នាលើនិយាមការ(ក្អរ៉ដោណេ)នៃកោះ ថ្មប៉ប្រះទឹក ចំណុចនីមួយៗ និងអ្វីៗទាំងអស់ ដែលមានលក្ខណៈពិសេស និងចរិតប្រវត្តិសាស្ត្រពាក់ព័ន្ធ ស្ថិតនៅក្នុងដែនដីគោក និងដែនសមុទ្រកម្ពុជា ថៃ។

(ឃ)-តាមដាន និងត្រួតពិនិត្យ ការអនុវត្តសន្ធិសញ្ញា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋាននានា។

**ប្រការ៣** : គណៈកម្មាធិការបច្ចេកទេសចម្រុះនេះ ត្រូវជួបប្រជុំគ្នាឲ្យបានទៀងទាត់ ក្នុងទស្សនៈសម្រេចឲ្យបាននូវការងាររបស់ខ្លួន ទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ ឲ្យបានឆាប់រហ័ស។ គណៈកម្មាធិការបច្ចេកទេសចម្រុះគ្នានេះ អាចបង្កើតឡើងនូវអនុគណៈកម្មាធិការ ឬក្រុមការងារដូចអ្វីដែលសមស្របទៅនឹងតម្រូវការចាំបាច់។

**ប្រការ៤** : គ្រប់សមាជិកនៃគណៈកម្មាធិការបច្ចេកទេសចម្រុះ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ហើយគណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញទីប្រឹក្សា និងអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ និងត្រូវរាយការណ៍ ជូនរាជរដ្ឋាភិបាលលើលទ្ធផលការងាររបស់ខ្លួន។

**ប្រការ៥** : គណៈកម្មាធិការបច្ចេកទេសចម្រុះនេះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៦**: គណៈកម្មាធិការបច្ចេកទេសចម្រុះនេះ មានសិទ្ធិប្រើប្រាស់មូលនិធិ ដែលជាចំណូលពីវិស័យប្រេងកាត នៃក្រសួងរ៉ែ និងថាមពល ក្នុងការបំពេញការងាររបស់ខ្លួន តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**ប្រការ៧**: សេចក្តីសម្រេចលេខ ៥៨ សសរ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ១០ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com